**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

លេខ...៦៦៤........បទ ស.ស.រ...........

បញ្ញត្តិករទូរគមនាគមន៍កម្ពុជា
ចូល លេខ......0663......ប.ក.ទ.ក.
ថ្ងៃទី...10...ខែ...03...ឆ្នាំ២០15
ម៉ោង...9H30...បញ្ជូន..............

# សេចក្តីសម្រេច
## ស្តីពីនីតិវិធីផ្ទេរការគ្រប់គ្រងចំណូលពីកម្រៃអាជ្ញាបណ្ណប្រេកង់ស៍, កម្រៃអាជ្ញាបណ្ណទូរគមនាគមន៍, កម្រៃលេខកូដទូរស័ព្ទ, និងកម្រៃសេវាគេហទំព័រ ពីបញ្ញត្តិករទូរគមនាគមន៍កម្ពុជា មកគ្រប់គ្រងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៣១២/១៧៥ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ ស្តីពីការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញអនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៣៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- យោងប្រកាសលេខ ១៩០១ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- យោងលិខិតរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លេខ១២៩បទ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ស្តីពីការផ្ទេរមុខសញ្ញាចំណូលពីបញ្ញត្តិករទូរគមនាគមន៍កម្ពុជាមកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។
- តាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

## សម្រេច

**ប្រការ ១..**

កំណត់នីតិវិធីផ្ទេរការគ្រប់គ្រងចំណូលពីកម្រៃអាជ្ញាបណ្ណប្រេកង់ស៍, កម្រៃអាជ្ញាបណ្ណទូរគមនាគមន៍, កម្រៃលេខកូដទូរស័ព្ទ(Telephone Numbering), និងកម្រៃសេវាគេហទំព័រ(DNS) ពីបញ្ញត្តិករទូរគមនាគមន៍កម្ពុជាមកគ្រប់គ្រងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ ២..**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ គ្រប់គ្រងការប្រមូលចំណូលដូចមានចែងក្នុងប្រការ១ ដើម្បីបង់ចូលថវិកាជាតិស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនៃឆ្នាំសារពើពន្ធនីមួយៗរបស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣..**

បញ្ញត្តិករទូរគមនាគមន៍កម្ពុជា មានភារកិច្ចត្រួតពិនិត្យ គ្រប់គ្រងខាងបច្ចេកទេស និងរដ្ឋបាល លើការស្តាបនា ការធ្វើប្រតិបត្តិការ ការផ្តល់ ការព្យួរ និងការដកហូតអាជ្ញាបណ្ណនិងលិខិតអនុញ្ញាត ពាក់ព័ន្ធនឹងការគ្រប់គ្រងមុខចំណូលដូចមានចែងក្នុងប្រការ១នៃសេចក្តីសម្រេចនេះ។

**ប្រការ ៤..**

រៀងរាល់ឆ្នាំសារពើពន្ធ (ឆ្នាំ "n") បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ត្រូវរៀបចំចេញអាជ្ញាបណ្ណប្រេកង់ស៍, លិខិតអនុញ្ញាតប្រើប្រាស់លេខកូដទូរស័ព្ទ និងលិខិតអនុញ្ញាតប្រើប្រាស់គេហទំព័រ ព្រមទាំងសារណាការការងារសម្រាប់ឲ្យប្រតិបត្តិករទូរគមនាគមន៍ អង្គភាព ឬអ្នកប្រើប្រាស់ សម្រាប់ការគ្រប់គ្រងឆ្នាំបន្ទាប់ (ឆ្នាំ "n+1")។

បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ត្រូវបញ្ជូនជាបណ្តើរៗចាប់ពីខែមករារហូតដល់ដំណាច់ឆមាសទី១ នៃឆ្នាំសារពើពន្ធនីមួយៗ (ឆ្នាំ "n+1") នូវបញ្ជីអាជ្ញាបណ្ណប្រេកង់ស៍, លិខិតអនុញ្ញាតប្រើប្រាស់លេខកូដទូរស័ព្ទ និងលិខិតអនុញ្ញាតប្រើប្រាស់គេហទំព័រ ព្រមទាំងភ្ជាប់សារណាការការងារជាច្បាប់ដើម និងអាជ្ញាបណ្ណប្រេកង់ស៍, លិខិតអនុញ្ញាតប្រើប្រាស់លេខកូដទូរស័ព្ទ និងលិខិតអនុញ្ញាតប្រើប្រាស់គេហទំព័រជាច្បាប់ចម្លងដែលមានបោះត្រាក្រហម សម្រាប់ការគ្រប់គ្រងឆ្នាំ"n+1" មកអគ្គនាយករដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីចាត់ចែងឲ្យអង្គភាពជំនាញពាក់ព័ន្ធរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍អនុវត្តបន្ត។

គ្រប់ការផ្តល់ថ្មីឬកែសម្រួល ការព្យួរ និងការដកហូតអាជ្ញាបណ្ណទូរគមនាគមន៍ បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ត្រូវបញ្ជូនអាជ្ញាបណ្ណ លិខិតព្យួរ និងលិខិតដកហូតជាច្បាប់ចម្លងដែលមានបោះត្រាក្រហមចំនួន០១ច្បាប់ មកអគ្គនាយករដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីចាត់ចែងឲ្យអង្គភាពជំនាញពាក់ព័ន្ធរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍អនុវត្តបន្ត។

**ប្រការ ៥.-**

បន្ទាប់ពីទទួលបញ្ជីអាជ្ញាបណ្ណប្រេកង់ស៍, លិខិតអនុញ្ញាតប្រើប្រាស់លេខកូដទូរស័ព្ទ, និងលិខិតអនុញ្ញាតប្រើប្រាស់គេហទំព័រ ព្រមទាំងភ្ជាប់សារណាការការងារជាច្បាប់ដើម និងអាជ្ញាបណ្ណប្រេកង់ស៍, លិខិតអនុញ្ញាតប្រើប្រាស់លេខកូដទូរស័ព្ទ និងលិខិតអនុញ្ញាតប្រើប្រាស់គេហទំព័រជាច្បាប់ចម្លងដែលមានបោះត្រាក្រហម ពីបញ្ញត្តិករទូរគមនាគមន៍កម្ពុជា អគ្គនាយករដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវចាត់បញ្ជូនឲ្យទៅនាយកដ្ឋានផែនការនិងហិរញ្ញវត្ថុ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីបន្តការងារចេញវិក្កយបត្រ កត់ត្រាតាមដានបំណុលត្រូវទារ និងប្រមូលចំណូលបង់ចូលថវិកាជាតិ។ ជាមួយគ្នានេះ ត្រូវចម្លងជូនអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ចំនួន០១ច្បាប់។

**ប្រការ ៦.-**

ក្នុងគោលបំណងសម្រួលដល់ប្រតិបត្តិករទូរគមនាគមន៍ អង្គភាព ឬអ្នកប្រើប្រាស់សេវា (តាមគោលការណ៍ច្រកចេញចូលតែមួយ) ក្នុងការស្នើសុំអាជ្ញាបណ្ណឬការអនុញ្ញាតនានា ការទទួលយកអាជ្ញាបណ្ណឬលិខិតអនុញ្ញាតនានា និងការបង់កម្រៃអាជ្ញាបណ្ណឬកម្រៃផ្សេងៗជូនក្រសួង អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវរៀបចំបន្ទប់ការិយាល័យមួយអមនៅនាយកដ្ឋានផែនការនិងហិរញ្ញវត្ថុ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សម្រាប់មន្ត្រីបញ្ញត្តិករទូរគមនាគមន៍កម្ពុជា បំពេញការងាររបស់ខ្លួន។

**ប្រការ ៧.-**

នាយកដ្ឋានផែនការនិងហិរញ្ញវត្ថុ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវរៀបចំរបាយការណ៍ចេញ

រិក្កយបត្រទាំងអស់ជូនរដ្ឋមន្ត្រី និងចម្លងជូនបញ្ញត្តិករទូរគមនាគមន៍កម្ពុជាចំនួន០១ច្បាប់។

រៀងរាល់ខែ ត្រីមាស ឆមាស និងឆ្នាំ នាយកដ្ឋានផែនការនិងហិរញ្ញវត្ថុនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវរៀបចំរបាយការណ៍ចំណូលពីកម្រៃអាជ្ញាបណ្ណប្រេកង់ស៍, កម្រៃអាជ្ញាបណ្ណទូរគមនាគមន៍ កម្រៃលេខកូដលេខទូរស័ព្ទ, និងកម្រៃសេវាគេហទំព័រ ជូនរដ្ឋមន្ត្រី និងចម្លងជូនបញ្ញត្តិករទូរគមនាគមន៍កម្ពុជាចំនួន០១ច្បាប់។

**ប្រការ ៨.-**

សេចក្តីសម្រេចទាំងឡាយណាមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩.-**

បញ្ញត្តិករទូរគមនាគមន៍កម្ពុជា អគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ប្រាក់ សុខុន**

**ចម្លងជូន ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី «ដើម្បីជ្រាប»
- ដូចប្រការ ៩ «ដើម្បីអនុវត្ត»
- ឯកសារ កាលប្បវត្តិ



កាច់ជ្រុងវិថីលេខ១៣ និង១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨០៩/៤២៨២៤៦
ទូរសារ (៨៥៥) ២៣-៤២៦៥៤១/៤២៦០០៥/៧២៤៨០៩